កាកបាទក្រហមកម្ពុជា

សាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ

**មតិស្វាគមន៍**

**របស់លោកជំទាវ ឌូ សុវណ្ណារី អភិបាលរងខេត្ត**

**និងជាប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ**

**ក្នុងពិធីប្រារព្ធខួបទី ១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ២០១៧**

**ក្រោមប្រធានបទ " កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា "**

**ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៧**

- សូមក្រាបថ្វាយបង្គំព្រះតេជគុណគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរពឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយ ខេត្តតាកែវ ជាទីគោរពដ៏ខ្ពង់ខ្ពស់។
- សូមគោរពឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលខេត្ត និងជាប្រធានកិត្តិយសសាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ និងលោកជំទាវ ជាទីគោរព។
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី អ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយស និងជាសមាជិក សមាជិកា នៃអង្គពិធីទាំងមូលជាទីគោរពរាប់អាន។

ថ្ងៃនេះ ជាទិវានក្ខត្តឫក្សដ៏ល្អប្រពៃ ដែលសាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ បានប្រារព្ធខួបទី ១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ២០១៧ ក្រោមប្រធានបទ " **កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ។

ក្នុងនាមសាខាកាកបាទក្រហមកម្ពុជាខេត្ត អនុសាខាក្រុង-ស្រុក ក្រុមកាកបាទក្រហមឃុំ សង្កាត់ និងមន្ទីរ អង្គភាព ជុំវិញខេត្ត និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវក្តីរីករាយជាអនេកប្បការ អបអរសាទរ ស្វាគមន៍ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុងឧត្តមថ្លៃថ្លា របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ និងសូមគោរពប្រសិទ្ធិពរមហា

បវរសួស្តី ជ័យមង្គលវិបុលសុខគ្រប់ប្រការដល់ ឯកឧត្តម និងលោកជំទាវ កូនប្រុស កូនស្រី ចៅប្រុស ចៅស្រី សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានរបស់ព្រះតេជគុណ ព្រះសង្ឃគ្រប់អង្គ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា សមាជិក សមាជិកា ព្រឹទ្ធសភា-រដ្ឋសភា-រាជរដ្ឋាភិបាលកម្ពុជា ក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ អាជ្ញាធរខេត្ត ក្រុង ស្រុក ថ្នាក់ដឹកនាំមន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ មន្ទីរ អង្គភាពជុំវិញខេត្ត អស់លោក លោកស្រី អ្នកនាង កញ្ញា តំណាងពាណិជ្ជករ អាជីវករ សប្បុរសជន លោកគ្រូ អ្នកគ្រូ យុវជន និងអ្នកស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា ដែលបានអញ្ជើញចូលរួមយ៉ាងច្រើនកុះករ ញ៉ាំងអោយអង្គពិធីទាំងមូលមានភាពមហោឡារិក អធិកអធមយ៉ាងក្រៃលែង។

**ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី-អ្នកនាងកញ្ញា និងអង្គពិធីទាំងមូលជាទីគោរព!**

ថ្ងៃនេះ ជាទិវាដ៏ឧត្តុង្គឧត្តមថ្លៃថ្លា ដែលសាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ បានប្រារព្ធខួបទីលើក១៥៤ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ ២០១៧ ក្រោមប្រធានបទ “ **កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា** ”

ការយកប្រធានបទនេះមានទស្សនទាន គឺចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម មានវត្តមាននៅគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា។ ជាមួយគោលការណ៍ភាពមិនលំអៀង និងអព្យាក្រឹត្យភាព ចលនាកាកបាទក្រហម អឌ្ឍចន្ទក្រហម ផ្តល់នូវក្តីសង្ឃឹម និងការជួយគាំទ្រខណៈពេលដែលមាន អ្នកត្រូវការអោយជួយជាចាំបាច់បំផុត ចលនាធ្វើសកម្មភាពដូចជាកម្លាំងមួយដែលធ្វើអោយមានការផ្លាស់ប្តូរជាវិជ្ជមាន នៅក្នុងសហគមន៍។ កាកបាទក្រហម អឌ្ឍចន្ទក្រហម មានវត្តមាននៅគ្រប់ទីកន្លែង ផ្តល់នូវការជួយគាំទ្រ ដល់ជនរងគ្រោះបំផុតគ្រប់ប្រភេទ ចាប់តាំងពីរងគ្រោះ ដោយគ្រោះមហន្តរាយធំៗ ការប្រឈមទៅនឹងស្ថានភាពជម្លោះនានា រហូតដល់ភាពងាយរងគ្រោះទាំងឡាយ នៅតាមតំបន់ជនបទដាច់ស្រយាលដែលគ្មាន អង្គការជំនួយណាមួយបានទៅដល់។

ឆ្នាំ២០១៦ កន្លងទៅនេះ អនុវត្តតាមយុទ្ធសាស្ត្រ ទស្សនវិស័យ បេសកកម្ម ព្រមទាំងអនុសាសន៍ដ៏មានតម្លៃរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជាផលផ្លែផ្ការីកដុះដាលរបស់កម្លាំងមនុស្សធម៌ និងវប្បធម៌ចែករំលែក សាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ បានធ្វើសកម្មភាព សម្រេចបានសមិទ្ធផលគួរឲ្យកត់សំគាល់ដូចខាងក្រោម៖ .

ទី១-បាននាំយកអំណោយមនុស្សធម៌ទៅចែកជូនប្រជាពលរដ្ឋ ដែលបានរងគ្រោះ គ្រប់ប្រភេទ ទូទាំងខេត្តមានដូចជា ខ្យល់កន្ត្រាក់ រន្ទៈបាញ់ស្លាប់ និងរបួស អគ្គិភ័យ លង់ទឹកស្លាប់ ជម្ងឺអេដស៍ ខ្សែភ្លើងឆក់ ធ្លាក់ពីលើដើមឈើស្លាប់ ចាស់ជរាទីទ័លក្រ ជនពិការ ពលអាហារ កម្មកររោងចក្រជួលសន្លប់ ស្ត្រីទើបឆ្លងទន្លេ និងគ្រួសារអតីតយុទ្ធជន បានចំនួន ៨៦លើក ស្មើនឹង ៤.៨៣៤គ្រួសារ។

សម្ភារៈដែលបានចែកជូនមានដូចជាស្បៀង គ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ សម្ភារៈសាងសង់ជម្រក និងលំនៅដ្ឋានជាដើម ។

សាខាបានសាងសង់ផ្ទះជូនប្រជាពលរដ្ឋទីទ័លក្រគ្មានទីពឹង ០១គ្រួសារ នៅស្រុកបាទី និងបានធ្វើការស្តារស្រះទឹក ទំហំ ៥០ ម៉ែត្រ គុណ ៦០ម៉ែត្រ ជំរៅ ៤ ម៉ែត្រ និងផ្លូវចូលស្រះប្រវែង ១៧០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេច កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ស្ថិតនៅភូមិត្បែម ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ទន្ទឹមនេះដែរ គណៈកម្មាធិការអនុសាខាក្រុង ស្រុកបានខិតខំស្វែងរកសម្ភារៈ ថវិកា ដើម្បី ដោះស្រាយជូនគ្រួសារប្រជាពលរដ្ឋរងគ្រោះនៅមូលដ្ឋានរបស់ខ្លួនផងដែរ ក្នុងនោះមានដូចជាអនុសាខាស្រុកបាទី អនុសាខាស្រុកគិរីវង់ និងអនុសាខាស្រុកសំរោងជាដើម ដែលជាការជួយសម្រាលបន្ទុករបស់សាខាកាកបាទក្រហមកម្ពុជាខេត្តផងដែរ។

ទី២-បានបើកវគ្គបណ្តុះបណ្តាលស្តីពីវិជ្ជាសង្គ្រោះបឋមដល់ នាយកសាលា គ្រូប្រចាំថ្នាក់ សិស្ស និស្សិត និងយុវជនកាកបាទក្រហមកម្ពុជាបានចំនួន ១៧វគ្គ នៅតាមវិទ្យាស្ថាន ១ វិទ្យាល័យ ១១ និងអនុវិទ្យាល័ ៣សាលា មានអ្នកចូលរួមចំនួន ១.០៤២នាក់ ស្រី ៤១៣នាក់។

ទី៣-បានសហការជាមួយកាកបាទក្រហមស្វីស អនុវត្តគំរោងលើកកម្ពស់សុខភាពបរិស្ថានសាធារណៈនៅកម្ពុជា ដោយអនុវត្តនៅស្រុកបាទី ចំនួន១៥ ឃុំ ស្មើ និង ១៦៨ ភូមិ ប្រជាពលរដ្ឋមានចំនួន ៣០.១៩៨គ្រួសារ ស្មើនឹង ១៥០.២៩១នាក់។

លើសកម្មភាព៖

-បណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមដល់អ្នកស្ម័គ្រចិត្ត និងយុវជន និងការផ្តល់សេវាសង្គ្រោះ បឋម។

-អប់រំផ្សព្វផ្សាយ ពីអនាម័យមានដូចជាការលាងសំអាតដៃ ការចែកធុងចំរោះទឹកស្អាត

ការសាងសង់បង្គន់អនាម័យ ការសំអាតបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។

-ការកែប្រែទម្លាប់ក្នុងការរស់នៅមានដូចជា ការប្រើប្រាស់ទឹកស្អាត (ផឹកស្អាត ហូបស្អាត និង រស់នៅស្អាត។

ទី៤-បានប្រារព្ធខួបទី ១៥៣ ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ ២០១៦ ក្រោមប្រធានបទ "**កាកបាទក្រហមកម្ពុជា មានគ្រប់ទីកន្លែង សម្រាប់គ្រប់ៗគ្នា** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលខេត្ត និងជាប្រធានកិត្តិយសសាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវ និងលោកជំទាវ នៅសាលមហោស្រពខេត្តតាកែវ កាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ ដោយទទួលបាន ថវិកាចំនួន **២៤៧.៦៤០,៦២** ដុល្លារអាមេរិក។

-សាខាបានធ្វើការណែនាំដល់អនុសាខាក្រុង ស្រុក ឲ្យជួយផ្សព្វផ្សាយស្តីពីការលើកកម្ពស់ការប្រើប្រាស់បដិរូប និងការពារបដិរូបកាកបាទក្រហម និងអឌ្ឍចន្ទក្រហមឲ្យបានត្រឹមត្រូវ ទៅតាមការណែនាំរបស់កាកបាទក្រហមកម្ពុជា។

-សាខាបានធ្វើការផ្សព្វផ្សាយស្តីពីសកម្មភាពរបស់សាខា តាមវិទ្យុ ទូរទស្សន៍បានចំនួន ៧៩លើក និងមានការផ្សព្វផ្សាយតាម បណ្តាញព័ត៌មានសង្គម (Facebook , WhatsApp) ជាដើម។

ទី៥-សាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ ឆ្នាំ២០១៦ មាន៖

-យុវជន ចំនួន៣.៣៨៣នាក់ ស្រី ២.២៣៨នាក់

-ទីប្រឹក្សា យុវជនចំនួន ១០៩នាក់ ស្រី ៥០នាក់ នៅតាមវិទ្យាស្ថាន ០១ វិទ្យាល័យចំនួន ៤៧ សាលា លើ ៤៧សាលា និងអនុវិទ្យាល័យចំនួន ០៧សាលា លើ ៧០សាលា ទូទាំងខេត្ត។

-យុវជនមាន ឯកសណ្ឋានចំនួន ២.៧២០នាក់

-មានប័ណ្ណសម្គាល់ខ្លួនចំនួន ២.៧២០នាក់

-យុវជនដែលបានទទួលការបណ្តុះបណ្តាលស្តីពីការយល់ដឹងពីកាកបាទក្រហមកម្ពុជា មានចំនួន ៩៤៣នាក់។

-បានផ្តល់ប័ណ្ណសរសើរដល់ទីប្រឹក្សាយុវជនកាកបាទក្រហមកម្ពុជាចំនួន ២០នាក់។

-សាខាបានទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាប័ត្រ សំរាប់សិស្ស-និស្សិតក្រីក្រពី **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** តាមរយៈកាកបាទក្រហមកម្ពុជា ជូនយុវជនសាខាកាកបាទក្រហមកម្ពុជាខេត្ត បានចំនួន ៥នាក់។

សាខាបានពង្រីកអ្នកស្ម័គ្រចិត្តបានគ្រប់អនុសាខាក្នុងខេត្ត ក្នុង ៣៣៥ភូមិ លើ ១.១១៩ ភូមិ មានចំនួនអ្នកស្ម័គ្រចិត្តសរុប ៧០៣នាក់ ស្រី ៣៨៣នាក់។

**ទី៦- អំពីចំណូល-ចំណាយ៖**

**ក-អំពីចំណូល៖**

ក្នុងឆ្នាំ ២០១៦កន្លងមកនេះ សាខាបានទទួលថវិកាមកពីប្រភពនានាមានដូចជា៖

| | |
|---|---|
| **សមតុល្យដើមឆ្នាំ ២០១៦** | **=183,604.75ដុល្លារ** |
| - ចំណូលសមាជិកភាព | = 3,328.40 ដុល្លារ |
| - ចំណូលប្រអប់វិភាគទាន | = 5,045.40 ដុល្លារ |
| - ចំណូលពីសប្បុរសជននានា | = 625 ដុល្លារ |
| - ចំណូលទិវា ៨ ឧសភា ២០១៦ | = 247,640.62 ដុល្លារ |
| - ចំណូលពីការប្រាក់ | = 4,748.39 ដុល្លារ |
| - ចំណូល ៦% ពីកាកបាទក្រហមស្វីស | = 5,260.43 ដុល្លារ |
| **សរុបចំណូល** | **= 266,648.24 ដុល្លារ** |

**សមតុល្យដើមឆ្នាំ ២០១៦ + ចំណូលឆ្នាំ ២០១៦** = **<u>450,253 ដុល្លារ</u>**

**ខ-អំពីចំណាយ៖**

សាខាបានចំណាយសម្រាប់សកម្មភាពមួយចំនួន ដើម្បីឆ្លើយតបទៅនឹងវិស័យស្នូលទាំង៤ មានដូចជា៖

| | |
|---|---|
| - ចំណាយគ្រោះមហន្តរាយ | = 191,219.84 ដុល្លារ |
| - ចំណាយរៀបចំទិវា ៨ ឧសភា ២០១៦ | = 8,645.75 ដុល្លារ |
| - ចំណាយលើការងារសុខភាព | = 21,201 ដុល្លារ |
| - ចំណាយលើគោលការណ៍គ្រឹះ | = 9,481 ដុល្លារ |
| - ចំណាយលើការងារអភិវឌ្ឍន៍ស្ថាប័ន | = 21,242.92 ដុល្លារ |
| - ចំណាយរដ្ឋបាល | = 4,267.47 ដុល្លារ |
| - ឧបត្ថម្ភបុគ្គលិក | = 27,740 ដុល្លារ |
| **សរុបចំណាយ** | **= 283,797.98 ដុល្លារ** |

**សមតុល្យគិតត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ឆ្នាំ២០១៧**

**មានចំនួន =<u>166,430.67ដុល្លារ</u>**

ក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមអង្គពិធីទាំងមូល និងថ្នាក់ដឹកនាំ អាជ្ញាធរដែនដី កងកំលាំងប្រដាប់អាវុធ គ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋទូទាំងខេត្ត ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការចំពោះសម្តេចវិបុលបញ្ញា **សុខ អាន និងលោកជំទាវ** ដែលជានិច្ចកាលសម្តេចតែងតែយកចិត្តទុកដាក់ជួយឧបត្ថម្ភគាំទ្រដល់ សាខាកាកបាទក្រហមកម្ពុជាខេត្តតាកែវមិនដែលខានឡើយ និងសូមថ្លែងអំណរគុណឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តតាកែវ ដែលឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ ជួយគាំទ្រដល់សកម្មភាពរបស់សាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា ឯកឧត្តម លោកជំទាវ-លោកឧកញ៉ា អស់លោក លោកស្រី អ្នកនាងកញ្ញា សមាជិក សមាជិកា សប្បុរសជនជាតិ អន្តរជាតិ ដៃគូសហប្រតិបត្តិការ រួមជាមួយនិងប្រជាជនខេត្តតាកែវទាំងមូល ពិតជានឹងបន្តចូលរួមចំណែកគាំទ្រ ទាំងស្មារតី សំភារៈ និងថវិកា ជួយដល់សាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ ដើម្បីអោយបេសកកម្មមនុស្សធម៌របស់យើង សំរេចបាននូវសមិទ្ធិផលថ្មីៗ ថែមទៀត ជូនជាតិ និងប្រជាពលរដ្ឋយើង ជាពិសេសនៅក្នុងការកាត់បន្ថយគ្រោះភ័យនានា ដោយមនុស្ស ដោយធម្មជាតិ និងជំងឺឆ្លងនានា។

សូមជូនពរឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី អ្នកនាងកញ្ញា និងអង្គពិធីទាំងមូលទទួលបាននូវសុខភាពល្អបរិបូរណ៌ អាយុយឺនយូរ មានសុភមង្គលក្នុងគ្រួសារ និងជ័យជំនះគ្រប់ភារកិច្ច គ្រប់កាលៈទេសៈ។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមគោរពអញ្ជើញឯកឧត្តម **ឡាយ វណ្ណៈ** អភិបាលនៃគណៈអភិបាលខេត្តតាកែវ មេត្តាអាននូវសេចក្តីថ្លែងការណ៍របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ទៅកាន់អង្គពិធីទាំងមូល សូមគោរពអញ្ជើញ។

**សូមអរគុណ !**